**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ៣៣៦
ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០០០
<u>សាលដីកា</u>
លេខៈ ២៥៤
ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០២

តាងនាមប្រជារាស្ត្រខ្មែរ
<u>តុលាការកំពូល</u>

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០០២ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក .................. ជាចៅក្រមរបាយការណ៍
៤-លោក ............... ជាចៅក្រម
៥-លោក ................ ជាចៅក្រម

<u>ក្រឡាបញ្ជី</u>

-កញ្ញា .......................

<u>តំណាងមហាអយ្យការ</u>

-លោក ................ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៥៥(ក)ចុះថ្ងៃទី០២ខែមិថុនាឆ្នាំ ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣០ ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ។

វាងដើមចោទឈ្មោះ កវស (ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥២ ឆ្នាំជាត់ខ្មែរមុខរបរលក់ដូរ មានទីលំនៅសព្វថ្ងៃទី ភូមិ ឃុំឬស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។ ឪពុកឈ្មោះ កែ សៀង (ស្លាប់) ម្តាយឈ្មោះ ព្រាប វ៉ាន់ (ស្លាប) ប្តីឈ្មោះ ឱន ឡោ មានកូន០៤ នាក់ ។

ចុងចម្លើយឈ្មោះ សសផ (ម្ចាស់បណ្តឹង សាទុក្ខ) ភេទប្រុស អាយុ៤១ឆ្នាំ ជាតិខ្មែរមុខរបរមេបញ្ជាការភូមិភាគ៥ មានទីលំនៅសព្វថ្ងៃទី ភូមិភាគ៥ ។ ឪពុកឈ្មោះ តូច ស៊ុន (រស់) ម្តាយឈ្មោះ ស លាភ (រស់) ប្រពន្ធឈ្មោះ ប៉ម សាម៉ែ មានកូន ០៤នាក់ ។ផ្ទេរសិទ្ធិឲ្យឈ្មោះ ហាក់ សិរីមុន្នី

<u>**កម្មវត្ថុបណ្តឹងៈ**</u> ទាមទារប្រាក់ថ្លៃស្តង់

បានឃើញបណ្តឹងសាទុក្ខលេខ ១៧៥ (ក) ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០០០ របស់ឈ្មោះ ហាក់ សិរីមុន្នី ប្តឹងមិនសុខចិត្ត និងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣៣៩ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ១៩៩៥ របស់អ្នកស្រី កវស ប្តឹងទាមទារប្រាក់ថ្លៃស្តង់ ពីលោក សសផ ដោយហេតុថា អ្នកស្រីបានជួលដីមួយកន្លែង ស្ថិតនៅទល់មុខសណ្ឋាគារស្រះស្ទួគ៍ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ពីអង្គភាពភូមិភាគទី៥ ដើម្បីធ្វើអាជីវកម្ម (បើកស្តង់លក់ត្រី) ដោយបានព្រមព្រៀងគ្នា ចុះកិច្ចសន្យាជួលក្នុងរយៈពេលមួយឆ្នាំម្តង គិតចាប់ពីថ្ងៃទី ១៨ខែកុម្ភៈ ឆ្នាំ១៩៩៤ ដល់ថ្ងៃទី ១៨ខែសីហា ឆ្នាំ១៩៩៤ ។ក្នុងកិច្ចសន្យាបានកំណត់យកថ្លៃឈ្នួល៦ខែមុនគិតថ្លៃឈ្នួល៦០០០បាត ក្នុងមួយខែ កាលបើផុតកំណត់៦ខែហើយ អ្នកស្រីត្រូវបង់ប្រចាំខែតទៅ ។ នៅពេលដាច់ឆ្នាំ១៩៩៤ ចូលឆ្នាំ១៩៩៥ អ្នកស្រីបានជួលដីនេះបន្តទៅទៀត ដោយមាត់ទទេ ពុំមានលាយល័ក្ខអក្សរឡើយ ដោយបានកំណត់ថ្លៃឈ្នួល តែ២០០០បាតក្នុងមួយខែ ព្រោះពេលនោះមានអសន្តិសុខ ហើយស្តង់ត្រី ក៏មិនមានដំណើរការ ។ លុះមកដល់ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ១៩៩៥ ស្រាប់តែលោកស្រី ចំរើន បាននាំកំលាំងមួយចំនួន ទៅរុះរើសំណង់របស់អ្នកស្រី ដោយពុំបានប្រាប់ជាមុនឡើយ ដោយសំអាងថាគេបានទិញដីនោះពីលោក នូវ សារឿន ដែលលោក សសផ បានផ្ទេរឲ្យជាកម្មសិទ្ធិ ដោយរំលោភលើកិច្ចសន្យារវាងអ្នកស្រី និងលោក សសផ ។

បានឃើញសាលក្រមរបៀបលេខ ៧៦ ចុះថ្ងៃទី ០៥ ខែវិច្ឆកា ឆ្នាំ១៩៩៦ របស់តុលាការខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ៖

១-ចាត់របៀបសាលក្រមលេខ ៧៦ ចុះថ្ងៃទី០៥ ខែវិច្ឆកា ឆ្នាំ១៩៩៦ ។

២-ឲ្យដើមចោទឈ្មោះ ឌិន ឡោ ជូនសំអាសាក្សី និងជាឯកសារសំអាងអំពីកិច្ចសន្យាផ្ទាល់មាត់ និងតម្លៃសំណង់ជាក់ស្តែងដែលត្រូវទាមទារ ។

៣-ឲ្យចុងចម្លើយឈ្មោះ សសផ ជូនសំអាងជាសាក្សី និងឯកសារផ្សេងៗដែលទាក់ទងទៅនឹងកិច្ចសន្យាផ្ទាល់មាត់ អំពីការសុំអនុញ្ញាជួសជុលលំអឃ្លាំងរបស់លោក ឲ្យក្លាយទៅស្តង់លក់ត្រី ដែលដើមចោទបានធ្វើកន្លងមក ។

៤-តុលាការនឹងបន្តសវនាការ លើរឿងនេះនៅក្រោយពេលប្រមូលភស្តុតាងថ្មីបានគ្រប់គ្រាន់ដើម្បីសម្រេច ។

៥-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ និងចុងចម្លើយ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៧២ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៩ របស់តុលាការខេត្តបន្ទាយមានជ័យ ដែលមានខ្លឹងសារ នៃសេចក្តីសម្រេចដូតទៅ ៖

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ១៩៩៤ របស់ដើមចោទឈ្មោះ កវស ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បង្គាប់ឲ្យលោក សសផ (ចុងចម្លើយ) បង់ប្រាក់ចំនួន១៣០.០០០បាត (ដប់បីម៉ឺនបាត) ជាសំណងជួសជុលការអន្តរាយសំណង់រោងថ្មី និងការ្យទាំងពួងដែលដើមចោទបានសង់បានធ្វើទៅលើដីជួល

ដោយសោហ៊ុយផ្ទាល់ខ្លួន ហើយត្រូវបានចុងចម្លើយផ្ទេរទៅឲ្យតតីជនលក់ដូរ និងរុះរើនាំយកចេញទៅអស់ ឲ្យទៅដើមចោទឈ្មោះ កវស ចាប់ពីថ្ងៃទីដែលសាលក្រមមានអនុភាពអនុវត្ត តទៅ ។បើដើមចោទទាមទារ លើសពីនេះ បដិសេធ ។ បើឈ្មោះ សសផ រឹងរូសមិនព្រមបង់ប្រាក់នេះទេ ឲ្យរឹបអូសទ្រព្យសម្បត្តិលក់ ឡាយឡុងជានាសំណង ឬឲ្យដាក់គុកបង្ខំដល់រូបកាយ តាមមាត្រា១២៥ និងមាត្រា១៣៣ នៃច្បាប់ស្តីពី វិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៣-ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី ពន្ធហ្នឹង ១៨០០៛ ប្រាក់រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ សោហ៊ុយរត់ដីកាកោះ ៥០០០៛ សរុប ៧០០០៛ ដែលដើមចោទបានបង់ទុករួចហើយ កាលបើផុតរយៈ ពេលប្តឹងឧទ្ធរណ៍ បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ ៧០០០៛ នោះសងទៅឲ្យដើមចោទវិញ និងបង្គាប់ឲ្យចុង ចម្លើយឈ្មោះ សសផ បង់ពន្ធសមាមាត្រ១% លើចំនួនទឹកប្រាក់ដែលត្រូវសងទៅឲ្យដើមចោទ ស្មើនឹង ១៣០០បាត ដើម្បីបង់ចូលថវិការដ្ឋ ៨០% ស្មើនឹង ១០៤០បាត និងដើម្បីបង់ចូលហិបប្រាក់ក្រឡា បញ្ជីទូទាំងប្រទេស ២០%ស្មើនឹង២៦០បាត ។

តាមមាត្រា៣៤,២២,២៣,១០០,១០១,១០៣,និងមាត្រា ១០៥ នៃក្រឹត្យច្បាប់លេខ ៣៨ក្រច ចុះ ថ្ងៃទី ២៨ ខែតុលាឆ្នាំ ១៩៩៨ ។

សាលក្រមនេះជំនុំជំរះជាសាធារណៈ ចំពោះមុខគូភាគីហើយបើកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ ច្បាប់ គិតពីថ្ងៃទីទទួលសាលក្រមនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៥៣ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ឈ្មោះ សសផ ប្តឹង មិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៧២ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៩ លើសាលក្រមទាំ ងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៥៥ ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០០០ របស់សាលា ឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

-សម្រេចមិនទទួលសំណុំរឿងក្តីរដ្ឋប្បវេណីលេខ ៣០ ចុះថ្ងៃទី១៣ ខែ០១ ឆ្នាំ២០០០ របស់ សាលាឧទ្ធរណ៍ ដោយដើមបណ្តឹងឧទ្ធរប្តឹងហួសកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៧៥ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០០០ របស់ឈ្មោះ ហាក់ សរី មុន្នី ប្តឹងមិនសុខចិត្តនឹងសាលដីកា ៥៥(ក) ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ លើ សេចក្តីសម្រេចទាំងមូល ។

-ចៅក្រមរបាយការណ៍អានរបាយការណ៍

-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថាៈ សាលាឧទ្ធរណ៍បានសម្រេចមកនេះមានលក្ខណៈ ត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេច ។

បានស្តាប់ចម្លើយរបស់ឈ្មោះ សិរីមុន្នី មកជំនួសឲ្យលោក សសផ នៅពេលជំនុំជំរះថាៈ ខ្លួនសូមជំរាបឯកឧត្តមជ្រាបថាៈ បានជាផុតអាណត្តិប្តឹង២ទូរណ៍ ពីព្រោះខ្លួនអត់បានទទួលដីកាកោះហៅ ឬ ចូលរួមក្នុងការកាត់ក្តីអ្វី ពីតុលាការខេត្តបន្ទាយមានជ័យទេ ដោយឈ្មោះ សសផ ជាប់បំពេញបេសកម្មផង តែដល់ផុតអាណត្តប្តឹង២ទូរណ៍ហើយ ទើបបានគេរុញមកឲ្យ ។ម្យ៉ាងទៀតអ្នកស្រី កវស មិនបានគោរពតាមកិច្ចសន្យា ដោយលោក សសផ បានចុះកុងត្រាជួលស្តង់ជាមួយ កវស ។ ដំបូងស្តង់នេះជួលបានក្នុង១ខែមួយម៉ឺនបាត តែដោយដើមចោទសុំបុក អណ្តូង និងជួសជុលកែលំអ ដើមចោទ ក៏សុំចុះត្រឹម ៦០០០បាត ដោយឲ្យបង់ថ្លៃឈ្នួល០៦ខែមុន ៣៦០០០បាត ។ដើមចោទក៏ខានបង់ឲ្យ០៦ខែ ដោយយកប្រាក់ទោឲ្យអ្នកផ្សេង ។ ពេលនោះប៉ោយប៉ែតក៏មានការវៃគ្នាយ៉ាងខ្លាំង ធ្វើឲ្យអ្នកស្រីមានការខាតបង់ក្នុងការប្រកបអាជីកម្ម ហើយអ្នកស្រី ក៏ឲ្យចុះថ្លៃ ២០០០បាត ព្រោះគាត់មានការលំបាកខ្លាំងណាស់ ។

បញ្ហារឿង សសផ ទទួលប្រាក់នោះ គាត់ពុំបានដឹងអ្វីទេ ។ ការបង់ថ្លៃឈ្នួលនេះគឺបង់បានតែ១ខែទេ ការទទួលប្រាក់ពីអ្នកស្រីនោះ ពុំបានទទួលតាមកិច្ចសន្យាទេ ។ក្រោយពីបានទទួលប្រាក់ឈ្នួលមក សសផ ក៏បានផ្ទេរទៅឲ្យ នៅ សារឿន លក់ដីនោះទៅ ។

ការជួសជុលសំណង់នោះគឺជួសជុលតែសំណង់ចាស់ទេ គ្មានសំណង់ថ្មីទេគ្រាន់តែជួសជុលឲ្យទូលាយតែប៉ុណ្ណោះ ។

បានស្តាប់ចម្លើយឈ្មោះ កវស នៅពេលជំនុំជំរះថាៈ លោក សសផមានមុខរហូតទើបតែឡើងមកសាលា២ទូរណ៍ទេ ទើបផ្ទេរឲ្យលោក ហាក់ សិរិមុន្នី ។

នៅឆ្នាំ ១៩៩០ ខ្លួនជួលដីឃ្លាំងពីចុងចម្លើយមានទំហំ១២ម x២៥ម ហើយខ្លួនបានជួលជុលសាងសង់បន្តភ្ជាប់ពីមុខឃ្លាំងទៅរោងចាស់ និងមានបុកគ្រឹះចាក់ដីឲ្យមាំ ដើម្បីងាយស្រួលឡានចូលមក ។

បញ្ហាបង់ថ្លៃឈ្នួល គឺជូនលុយផ្ទាល់ ដោយក្តីរាប់អាន ពុំបានធ្វើវិក័យបត្រទេ ប្រហែល៣ខែក្រោយមក សភាពការណ៍សន្តិសុខ កើតឡើងខ្ញុំក៏ជួបការលំបាកណាស់ខ្ញុំក៏សុំឲ្យចុះថ្លៃឈ្នួល ២០០០បាត ពេលនោះខ្ញុំក៏បង់បាន២ខែស្រប់តែគាត់ផ្ទេរសិទ្ធិឲ្យទៅ នៅ សារឿន ដើម្បីលក់ តែមុនគាត់លក់នេះគាត់ក៏បានប្រាប់ខ្លួនដែរថា ទិញដីនេះទៅគាត់លក់តែ៣០ម៉ឺនបាតទេ ខ្លួនថាគ្មានប្រាក់ទេបើអញ្ចឹងទុកលឲ្យខ្លួនលក់វិញ ព្រោះមានសំណង់របស់ខ្លួននៅលើដីនេះ ហើយម្យ៉ាងទៀត ខ្លួនពុំបានជំពាក់ថ្លៃឈ្នួលទេ គ្រាន់តែសុំចុះថ្លៃឈ្នួលតែប៉ុណ្ណោះ ។

ខ្លួនគ្រាន់តែប្តឹង សុំទាមទាររុះយកសំណង់ របស់ខ្លួនមកវិញទេ ហើយដីនោះគេបានលក់នៅឆ្នាំ ១៩៩៥ ឯខ្លួនក៏បានប្តឹងពីឆ្នាំ១៩៩៥ រហូតមក៧ឆ្នាំហើយ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៧៥ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០០០ របស់ឈ្មោះ ហាក់ សិរីមុន្នី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា តុលាការខេត្តបន្ទាយមានជ័យបានជំនុំជំរះនៅថ្ងៃទី ០១ ខែកក្កដា ឆ្នាំ១៩៩៩ ចំពោះមុខគូក្តី ប៉ុន្តែចុងចម្លើយបានប្តឹងឧទ្ធរណ៍ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ១៩៩៩ ដែលតាមមាត្រា ៧ វាក្យខ័ណ្ឌ១ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលជំរះក្តី ក៏ដូចជាមាត្រា១៨៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ចុងចម្លើយបានប្តឹងឧទ្ធរណ៍ហួសកាលកំណត់ នៃច្បាប់ដូច្នេះ ការដែលសាលាឧទ្ធរណ៍ពុំពិចារណា លើបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ សសផ គឺជាការត្រឹមត្រូវហើយ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៥៥ (ក) ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ដែលសម្រេច សេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខ គូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ១៧៥ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០០ របស់ ហាក់ សិរីមុន្នី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ៥៥ (ក) ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០០ របស់សាលឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩០០០៛ ដែលឈ្មោះ សសផ បានបង់ទុកនៅតុលាការកំពូលគឺ ៖

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ។

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥០០០៛ សរុប ១៩០០០៛

-បង្គាប់ឲ្យឈ្មោះ សសផ បង់ពន្ធសមាមាត្រ១% តាមកាកំណត់របស់តុលាការថ្នាក់ក្រោម ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០០២ ។